# គណបក្សសង្គ្រោះជាតិ

# CAMBODIA NATIONAL RESCUE PARTY

**សង្គ្រោះ បម្រើ ការពារ**

## ជម្រាបជូន

## បងប្អូនជនរួមជាតិនៅរដ្ឋ Washington, U.S.A

តាងនាមគណបក្សសង្គ្រោះជាតិ ខ្ញុំសូមសម្តែងនូវសេចក្តីរំភើប និងកោតសរសើរឥតឧបមាចំពោះបងប្អូនដែលបានរៃអង្គាសថវិកាសរុបចំនួន ១៥.៣៦៧ **(មួយម៉ឺនប្រាំពាន់បីរយហុកសិបប្រាំពីរ)** ដុល្លារសហរដ្ឋអាមេរិក និងបានផ្តល់ថវិកានេះមកជួយឧបត្ថម្ភគណបក្ស និងកិច្ចការសង្គមកិច្ច តាមរយៈគណនីគណបក្ស ។

ឥរិយាបថប្រកបដោយសប្បុរសធម៌របស់បងប្អូន គឺជាវិភាគទានដ៏ថ្លៃថ្លាក្នុងការចូលរួមចំណែកជួយឧបត្ថម្ភគណបក្ស ក្នុងសកម្មភាពមនុស្សធម៌ និងក្នុងដំណើរការតស៊ូ ដើម្បីទាមទារលទ្ធិប្រជាធិបតេយ្យ សិទ្ធិ សេរីភាព និងយុត្តិធម៌សង្គម នៅក្នុងមាតុប្រទេសរបស់យើង ។

ជួសមុខឲ្យគណបក្សសង្គ្រោះជាតិ ក៏ដូចជាថ្នាក់ដឹកនាំទាំងអស់ ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅចំពោះបងប្អូន ដែលមានទឹកចិត្តដ៏វិសេសវិសាលនេះ ហើយសូមប្រសិទ្ធិពរដល់បងប្អូនប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមបងប្អូន ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ៕

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤

**ប្រធានស្តីទីគណបក្ស**

**អ៊ូ ច័ន្ទឫទ្ធិ**

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House #576, National Road N°2, Sangkat Chakangres Leu, Khan Mean Chey, Phnom Penh, Kingdom of Cambodia
Tel : 012 90 57 75 / 092 92 51 71 / Email: cnrpcabinet@gmail.com